ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តស្វាយរៀង
គណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត
លេខ07/18.សជណ

សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃការងារ

១-ការងារសាងសង់ការិយាល័យច្រកចេញចូលតែមួយក្នុងសាលាខេត្តស្វាយរៀង ដែលមានបណ្តោយ២៥,៥០ម ទទឹង៩ម អំពីបេតុង ជញ្ជាំងរៀបឥដ្ឋ ប្រក់ក្បឿងស៊ីម៉ង់ត៍ ក្រាលការ៉ូបាត លាបស្ពិចត្រូលក្នុង-ក្រៅ និងបំពាក់បណ្តាញទឹក ភ្លើង ។

២-ការងារជួសជុលផ្សារតាហោ សង្កាត់ពោធិតាហោ ក្រុងស្វាយរៀង ដោយប្តូរដំបូលថ្មី ព្រមទាំងទរទឹក ស្តារដីក្នុងលូដាឡនិងប្តូរគម្របដាឡ រុះរើរបងចាស់ធ្វើរបងថ្មី ចាក់បេតុងអាម៉េផ្លូវចូលពីកើត និងដាក់លូរំដោះទឹកចេញពីផ្សារមុខកាត់0,៥0មប្រវែង២២ម។

៣-ការងារជួសជុលផ្សារកំពង់ត្រាច ទីរួមស្រុករមាសហែក ដោយធ្វើការស្តារដីពីលូដាឡ និងប្តូរគម្របដាឡប្តូរផ្លាន ដៃរណែង និងស័ង្កសីដំបូលដែលខូចចោលអស់។

៤-ការងារសាងសង់ការិយាល័យច្រកចេញចូលតែមួយ មួយខ្នង នៅសាលាស្រុកស្វាយជ្រំដែលមាន បណ្តោយ២០មទទឹង១៤មជាន់ផ្ទាល់ដី សង់អំពីបេតុង ជញ្ជាំងរៀបឥដ្ឋ ប្រក់ក្បឿងស៊ីម៉ង់ត៍ ក្រាលការ៉ូ បាត លាបស្ពិចត្រូលក្នុង-ក្រៅ និងបំពាក់បណ្តាញទឹកភ្លើងជូនសាលាខេត្តស្វាយរៀង។

រដ្ឋបាលខេត្តស្វាយរៀង សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនក្នុងស្រុក (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា៖ រដ្ឋបាលខេត្តស្វាយរៀង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួលការ ជួសជុល ខាងលើជូនសាលាខេត្តស្វាយរៀង។

រដ្ឋបាលខេត្តស្វាយរៀង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្តស្វាយរៀង អាសយដ្ឋានសាលាខេត្តស្វាយរៀង ចាប់ពីថ្ងៃទី..១៨.....ខែ..១០.......ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការ ដល់វេលា ម៉ោង...................... ថ្ងៃទី............ខែ................ឆ្នាំ២០១៨ ។

ឯកសារដេញថ្លៃដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្តយ៉ាងយូរបំផុតត្រឹមថ្ងៃទី..១៧......ខែ..តុលា.....ឆ្នាំ២០១៨ វេលាម៉ោង..៨.ព្រឹក.......។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅ នៅអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្ត តាមអាសយដ្ឋានខាងលើ (សាលាខេត្តស្វាយរៀង) វេលាម៉ោង..៩.ព្រឹក.......ថ្ងៃទី..១៧.....ខែ..តុលា....ឆ្នាំ២០១៨ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មរបស់រដ្ឋបាលខេត្តស្វាយរៀង ដើម្បីទិញឯកសារដេញថ្លៃ និង សាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃ...ពុធ.....៩..រោច.........ខែ...ភទ្របទ....ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
នៅស្វាយរៀង,ថ្ងៃទី....០៣....ខែ...តុលា......ឆ្នាំ២០១៨

អភិបាលខេត្ត និងជា
ប្រធានគណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត

ប្រាក់ សុវណ្ណ

ចម្លងជូន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារកាលប្បវត្តិ